**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៦៧ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការចរចាជាមួយក្រុមហ៊ុនអាកាសចរណ៍ជាតិវៀតណាម ក្នុងការបង្កើតក្រុមហ៊ុនអាកាសចរណ៍ជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការចរចាជាមួយក្រុមហ៊ុនអាកាសចរណ៍ជាតិវៀតណាម ក្នុងការបង្កើតក្រុមហ៊ុនអាកាសចរណ៍ជាតិកម្ពុជា ដែលមានសមាសភាពដូចរាយនាមខាងក្រោម ÷

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **សេង លឹមនៅ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២. ឯកឧត្តម | **សុខ ចិន្តា** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៣. ឯកឧត្តម | **សយ សុខា** | អគ្គលេខាធិការរងទី ១ រាជរដ្ឋាភិបាល | អនុប្រធាន |
| ៤. ឯកឧត្តម | **គីតវ៉េត សំរេច** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥. ឯកឧត្តម | **ជា វ៉ាន់ដេត** | ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន | សមាជិក |
| ៦. ឯកឧត្តម | **ហ៊ាន សាហ៊ីប** | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

www.pheakdeylaw.com

| | | | | |
|---|---|---|---|---|
| ៧. | ឯកឧត្តម | សយ សុខាន់ | អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ៨. | ឯកឧត្តម | ជា អូន | អគ្គនាយក នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ៩. | ឯកឧត្តម | សុខ ខាទ៉ាន់ | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ១០. | លោក | សុខ សុភាន | នាយករងខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១១. | លោក | ទ៉ាន់ ចន្ទី | ជំនួយការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |

**ប្រការ ២ :** គណៈកម្មការចរចាជាមួយក្រុមហ៊ុនអាកាសចរណ៍ជាតិវៀតណាមមានភារកិច្ចដូចខាងក្រោម ÷

- ធ្វើការចរចា និងសម្របសម្រួលការងារជាមួយក្រុមហ៊ុនអាកាសចរណ៍ជាតិវៀតណាម
- ធ្វើការវិភាគ និងវាយតម្លៃពីសមិទ្ធិលទ្ធភាព កិច្ចសន្យា និងលក្ខខណ្ឌនានា នៃសម្ព័ន្ធអាជីវកម្មរបស់ក្រុមហ៊ុនអាកាសចរណ៍ជាតិកម្ពុជា
- ដោះស្រាយ សម្របសម្រួលរាល់បញ្ហាដែលកើតមានឡើងនៅក្នុងដំណើរការនៃការចរចា
- ធ្វើរបាយការណ៍អំពីលទ្ធផល នៃការចរចា និងលើកយោបល់ជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសម្រេច

**ប្រការ ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com